**វេទិកាកំរិតខ្ពស់**

**ក្រុងប៉ារីស ថ្ងៃទី២៨ ខែកុម្ភៈ ដល់ថ្ងៃទី២ ខែមិនា ឆ្នាំ២០០៥**

# សេចក្តីថ្លែងការណ៍ក្រុងប៉ារីសស្តីពីប្រសិទ្ធភាពនៃជំនួយ

***ភាពជាម្ចាស់ សុខដុមនីយកម្ម ការសំរបសំរួល លទ្ធផល និងការទទួលខុសត្រូវរួមគ្នា***

## ១.សេចក្តីថ្លែងនូវឆន្ទៈ

១. យើងទាំងអស់គ្នា ដែលជារដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ នៃបណ្តាប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ និងប្រមុខនៃស្ថាប័នអភិវឌ្ឍន៍ទ្វេភាគីនិងពហុភាគី បានជួបប្រជុំគ្នានាទីក្រុងប៉ារីស កាលពីថ្ងៃទី២ ខែមិនា ឆ្នាំ២០០៥ សូមប្តេជ្ញាថានឹងអនុវត្តនូវសកម្មភាពចាំបាច់និងសមស្របទាំងឡាយ សំដៅធ្វើការកែប្រែទំរង់ការនៃការផ្តល់ជំនួយនិងការគ្រប់គ្រងជំនួយ ក្នុងខណៈពេលដែលយើងសម្លឹងឆ្ពោះទៅរកការពិនិត្យរួមគ្នាសំរាប់រយៈពេលប្រាំឆ្នាំ អំពីវឌ្ឍនភាពក្នុងការអនុវត្តន៍សេចក្តីថ្លែងការណ៍សហសវត្សរ៍ និងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ដែលត្រូវធ្វើដោយអង្គការសហប្រជាជាតិនាដំណាច់ឆ្នាំនេះ ។ ដូចនៅក្នុងកិច្ចប្រជុំនាទីក្រុង Monterrey ដែរ យើងទទួលស្គាល់ថា ខណៈដែលយើងត្រូវបង្កើនបរិមាណជំនួយនិងធនធានអភិវឌ្ឍន៍ ដើម្បីសំរេចអោយបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ប្រសិទ្ធភាពជំនួយក៏ត្រូវធ្វើអោយប្រសើរជាងមុនខ្លាំងផងដែរ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសជាដៃគូក្នុងការពង្រឹងអភិបាលកិច្ច និងអនុវត្តសកម្មភាពអភិវឌ្ឍន៍ ។ ប្រការនេះរឹងរឹតតែមានសារសំខាន់បន្ថែមទៀត បើគំនិតផ្តួចផ្តើមដែលមានស្រាប់និងថ្មីៗរបស់ប្រទេសនិងស្ថាប័នអភិវឌ្ឍន៍ទ្វេភាគីនិងពហុភាគី អាចនាំអោយមានការបង្កើនទំហំនៃការផ្តល់ជំនួយ ។

២. នៅក្នុងវេទិកាលើកនេះ យើងបានពិនិត្យមើលពីសេចក្តីថ្លែងការណ៍ដែលបានប្រកាសក្នុងវេទិកាកំរិតខ្ពស់ស្តីពីសុខដុមភាវូបនីយកម្ម នាទីក្រុងរ៉ូម កាលពីខែកុម្ភៈ ឆ្នាំ២០០៣ និងគោលការណ៍សំខាន់ៗដែលបានប្រកាសនៅឯកិច្ចប្រជុំតុមូល Marrakech ស្តីពីការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ដើម្បីលទ្ធផល កាលពីខែកុម្ភៈ ឆ្នាំ២០០៤ ពីព្រោះយើងមានជំនឿថា គោលការណ៍ទាំងនេះនឹងលើកកំពស់ប្រសិទ្ធភាពរបស់ជំនួយ ក្នុងការកាត់បន្ថយភាពក្រីក្រនិងវិសមភាព ជំរុញកំណើនសេដ្ឋកិច្ច កសាងសមត្ថភាព និងជំរុញការសំរេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ។

### បង្កើនការផ្តល់ជំនួយប្រកបដោយប្រសិទ្ធភាពបន្ថែមទៀត

៣. យើងសូមអះអាងសាជាថ្មីនូវការប្តេជ្ញាចិត្តដែលបានធ្វើនៅទីក្រុងរ៉ូម ដើម្បីធ្វើសុខដុមភាវូបនីយកម្ម និងសំរបសំរួលការផ្តល់ជំនួយ ។ យើងបានទទួលការលើកទឹកចិត្ត ដោយប្រទេសផ្តល់ជំនួយ និងប្រទេសជាដៃគូជាច្រើន បានចាត់ទុកការលើកកំពស់ប្រសិទ្ធភាពជំនួយជាអាទិភាពខ្ពស់បំផុតមួយ និងសូមអះអាងសាជាថ្មីនូវការប្តេជ្ញាចិត្តរបស់យើងក្នុងការជំរុញអោយមានវឌ្ឍនភាពក្នុងការអនុវត្តន៍សកម្មភាពខាងក្រោមនេះ ÷

- ពង្រឹងយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍ជាតិរបស់ប្រទេសជាដៃគូ និងក្របខ័ណ្ឌសំរាប់កិច្ចប្រតិបត្តិការនានា ក្នុងការអនុវត្តន៍យុទ្ធសាស្ត្រទាំងនោះ (ការធ្វើផែនការ ថវិកា និងការរៀបចំក្របខ័ណ្ឌសំរាប់វាយតំលៃការអនុវត្តន៍សកម្មភាព) ។
- បង្កើនការផ្តល់ជំនួយអោយស្របទៅនឹងអាទិភាព រចនាសម្ព័ន្ធស្ថាប័ននិងនីតិវិធីប្រតិបត្តិរបស់ប្រទេសជាដៃគូ ព្រមទាំងគាំទ្រអោយមានការពង្រឹងសមត្ថភាព ។
- លើកកំពស់ការទទួលខុសត្រូវរបស់ម្ចាស់ជំនួយនិងប្រទេសជាដៃគូ ចំពោះមុខប្រជាពលរដ្ឋនិងស្ថាប័ននីតិបញ្ញត្តិរបស់ខ្លួន លើគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍ ព្រមទាំងការអនុវត្តន៍នូវគោលនយោបាយនិងយុទ្ធសាស្ត្រទាំងនោះ ។
- លុបបំបាត់កិច្ចខិតខំប្រឹងប្រែងដែលមានលក្ខណៈជាន់គ្នា និងធ្វើសនិទានកម្មរាល់សកម្មភាពរបស់អ្នកផ្តល់ជំនួយដើម្បីអោយមានប្រសិទ្ធភាពនិងចំណាយតិច ។
- កែសំរួលនិងធ្វើអោយសាមញ្ញ បណ្តាគោលនយោបាយនិងនីតិវិធីប្រតិបត្តិរបស់អ្នកផ្តល់ជំនួយ ដើម្បីជំរុញសហប្រតិបត្តិការ និងប្រែក្លាយការផ្តល់ជំនួយអោយស្របជាមួយអាទិភាព រចនាសម្ព័ន្ធស្ថាប័ននិងនីតិវិធីប្រតិបត្តិរបស់ប្រទេសជាដៃគូ ។
- កំណត់នូវកំរិតនៃសមត្ថភាពបំពេញភារកិច្ចនិងការទទួលខុសត្រូវ នៃរចនាសម្ព័ន្ធស្ថាប័នរបស់ប្រទេសជាដៃគូ ក្នុងកិច្ចការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការងារលទ្ធកម្ម អភិបាលកិច្ចនិងការវាយតំលៃបរិស្ថាន អោយស្របតាមគោលការណ៍សំរាប់ការអនុវត្តន៍ល្អដែលទទួលស្គាល់ជាសាកល និងដើម្បីអនុវត្តអោយបានឆាប់រហ័ស និងទូលំទូលាយ ។

៤. យើងប្តេជ្ញានឹងអនុវត្តអោយមានប្រសិទ្ធភាព វិធានការសំដៅឆ្លើយតបនឹងបញ្ហាប្រឈមទាំងឡាយដែលមាននាពេលបច្ចុប្បន្ន ដែលរួមមាន ÷

ក- ភាពទន់ខ្សោយខាងផ្នែកសមត្ថភាពស្ថាប័នរបស់ប្រទេសជាដៃគូ ក្នុងការរៀបចំនិងអនុវត្តន៍យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

ខ- ការខកខានក្នុងការសន្យាផ្តល់ជំនួយដែលអាចប៉ាន់ប្រមាណបាន និងសំរាប់រយៈពេលច្រើនឆ្នាំ ។

គ- ការធ្វើប្រតិភូកម្មសិទ្ធិសំរេចមិនបានពេញលេញអោយដល់បុគ្គលិករបស់អ្នកផ្តល់ជំនួយ ដែលបំរើការនៅក្នុងប្រទេសជាដៃគូ និងការមិនបានផ្តល់ការលើកទឹកចិត្តអោយបានសមស្រប ដល់ការកសាងភាពជាដៃគូរវាងម្ចាស់ជំនួយនិងប្រទេសជាដៃគូ ។

ឃ- ការធ្វើសមាហរណកម្មមិនបានពេញលេញ នូវកម្មវិធីនិងគំនិតផ្តួចផ្តើមដែលមានលក្ខណៈជាសកលចូលទៅក្នុងកម្មវិធីអភិវឌ្ឍន៍របស់ប្រទេសជាដៃគូ ដូចជាបញ្ហាជំងឺអេដស៍ជាដើម ។

ង- អំពើពុករលួយនិងកង្វះតម្លាភាព ដែលនាំអោយបាត់បង់នូវការគាំទ្រពីសាធារណជន និងជាឧបសគ្គដល់ការកៀងគរនិងបែងចែកធនធានប្រកបដោយប្រសិទ្ធភាព សំរាប់កាត់បន្ថយភាពក្រីក្រ និងកិច្ច

អភិវឌ្ឍន៍ប្រកបដោយចីរភាព ។ អំពើពុករលួយក៏ជាឧបសគ្គដល់ការប្រើប្រាស់ប្រព័ន្ធរបស់ប្រទេសជាដៃគូផងដែរ ។

៥. យើងទទួលស្គាល់ថា ការលើកកំពស់ប្រសិទ្ធភាពជំនួយគឺជាការចាំបាច់និងអាចធ្វើទៅបាន សំរាប់គ្រប់ទំរង់ការនៃការផ្តល់ជំនួយ ។ ក្នុងការសំរេចពីទំរង់ការនៃការផ្តល់ជំនួយ យើងនឹងអនុលោមតាមយុទ្ធសាស្រ្ត និងអាទិភាពដែលកំណត់ដោយប្រទេសជាដៃគូ ។ យើងនឹងបង្កើតទំរង់ការគាំទ្រផ្សេងៗទៀត ក្នុងលក្ខណៈឯកតោភាគីក្តី ឬជារួមក្តី ដើម្បីបង្កើនអោយបានជាអតិបរមានូវប្រសិទ្ធភាពរួមរបស់ជំនួយ ។

៦. ជាការឆ្លើយតបនឹងសេចក្តីប្រកាសក្រុងរ៉ូម យើងនឹងបន្តប្រឹងប្រែងបង្កើនទំហំការផ្តល់ជំនួយដូចដែលបានសន្យានៅ Monterrey និងប្រើប្រាស់ជំនួយទាំងនោះ ដោយមិនបន្ថែមបន្ទុកសំរាប់ប្រទេសជាដៃគូឡើយ ។

## ការតំរូវតាមស្ថានភាពរបស់ប្រទេសនីមួយៗ

៧. ការបង្កើនប្រសិទ្ធភាពជំនួយជាប្រការចាំបាច់ផងដែរ ក្នុងកាលៈទេសៈដែលមានលក្ខណៈប្រឈមខ្លាំង និងមានភាពស្មុគស្មាញ ដូចជាក្នុងករណីព្យុះរលកសមុទ្រ Tsunami ដែលបានបោកបក់ទៅលើប្រទេសមួយចំនួននៅជាប់មហាសមុទ្រឥណ្ឌា កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៤ ។ នៅក្នុងស្ថានភាពបែបនេះ ជំនួយអភិវឌ្ឍន៍ និងមនុស្សធម៌ទូទាំងពិភពលោក ត្រូវតែធ្វើសុខដុមនីយកម្មជាមួយនឹងក្របខ័ណ្ឌកំណើន និងការកាត់បន្ថយភាពក្រីក្ររបស់ប្រទេសជាដៃគូ ។ ក្នុងករណីរដ្ឋដែលទទួលរងវិបត្តិ ស្របពេលជាមួយនឹងការគាំទ្រកិច្ចនីតិសម្បទាស្ថាប័នសំខាន់ៗរបស់រដ្ឋ និងការផ្តល់សេវាចាំបាច់មួយចំនួន យើងនឹងធានាថាគោលការណ៍នៃការធ្វើសុខដុមនីយកម្ម ការតំរែតំរង់ជំនួយ និងការគ្រប់គ្រងប្រកបដោយលទ្ធផល នឹងត្រូវបានសំរបសំរួលទៅតាមស្ថានភាពអភិបាលកិច្ចនិងសមត្ថភាពទន់ខ្សោយរបស់ប្រទេសដែលជាដៃគូ ។ ជារួម យើងនឹងយកចិត្តទុកដាក់អោយបានខ្លាំងក្លា ចំពោះស្ថានភាពដែលមានលក្ខណៈស្មុគ្រស្មាញបែបនេះ ។

## សូចនាករតាមដាន កាលបរិច្ឆេទ និងគោលដៅ

៨. យើងទទួលស្គាល់ថាការប្តេជ្ញាចិត្តដែលបានប្រកាសចេញនៅក្នុងសេចក្តីប្រកាសនេះ ទាមទារអោយមានកិច្ចគាំទ្រផ្នែកនយោបាយកំរិតខ្ពស់ជាប្រចាំ ការជំរុញពីខាងក្រៅ និងសកម្មភាពស៊ីសង្វាក់គ្នាក្នុងកំរិតសកលតាមតំបន់ និងប្រទេស ។ យើងប្តេជ្ញាបង្កើនល្បឿនការអនុវត្តន៍ដើម្បីសំរេចអោយបាននូវបំលាស់ប្តូរទាំងនេះក្នុងស្មារតីទទួលខុសត្រូវទៅវិញទៅមក ស្របតាមគោលការណ៍ភាពជាដៃគូដូចមាននៅក្នុងចំណុចទី២នៃសេចក្តីប្រកាសនេះ និងវាស់ស្ទង់នូវវឌ្ឍនភាពនៃការអនុវត្តន៍របស់យើង ផ្អែកលើសូចនាករសំរាប់តាមដាន១២ ដែលយើងបានព្រមព្រៀងគ្នានៅថ្ងៃនេះ ដូចដែលមាននៅក្នុងចំណុចទី៣នៃសេចក្តីប្រកាសនេះ ។

៩. ការជំរុញបន្ថែមទៀត យើងកំណត់សំរេចវឌ្ឍនភាពអោយបានត្រឹមឆ្នាំ២០១០ ។ គោលដៅដែលបានកំណត់ទាំងនេះ រួមបញ្ចូលទាំងសកម្មភាពពីភាគីម្ចាស់ជំនួយនិងភាគីប្រទេសជាដៃគូ សំរាប់ធ្វើការតាមដាន

វឌ្ឍនភាព ក្នុងកំរិតសកលលោក ក្នុងចំណោមបណ្តាប្រទេសនិងទីភ្នាក់ងារដែលបានធ្វើការប្តេជ្ញាចិត្ត នៅក្នុងសេចក្តីប្រកាសនេះ ។ គោលដៅដែលបានកំណត់ទាំងនេះ នឹងមិនមែនជាមូលដ្ឋានសំរាប់ធ្វើបុរេវិនិច្ឆ័យ ឬក៏សំរាប់ជំនួសគោលដៅដែលប្រទេសជាដៃគូនីមួយៗបានកំណត់នោះទេ ។ នៅថ្ងៃនេះ យើងបានព្រមព្រៀងគ្នាកំណត់គោលដៅជាបឋម៥របស់សូចនាករដែលមាននៅក្នុងចំណុចទី៣ ។ យើងបានយល់ព្រមផងដែរថានឹងពិនិត្យមើលពីគោលដៅទាំង៥នេះម្តងទៀត និងកំណត់គោលដៅដែលនៅសេសសល់អោយបានមុនមហាសន្និបាតអង្គការសហប្រជាជាតិ នៅក្នុងខែកញ្ញា ឆ្នាំ២០០៥ ខាងមុខនេះ ។ ក្នុងន័យនេះ យើងនឹងស្នើសុំអោយមានភាពជាដៃគូរវាងម្ចាស់ជំនួយនិងប្រទេសជាដៃគូ ក្នុងការរៀបចំការងារដ៏បន្ទាន់នេះ ។ ទន្ទឹមនេះ យើងស្វាគមន៍នូវរាល់គំនិតផ្តួចផ្តើមរបស់ប្រទេសជាដៃគូនិងម្ចាស់ជំនួយ ក្នុងការកំណត់គោលដៅរបស់ខ្លួនសំរាប់កែលំអប្រសិទ្ធភាពជំនួយ នៅក្នុងក្របខ័ណ្ឌនៃការប្តេជ្ញានិងសូចនាករដែលបានព្រមព្រៀងនៅក្នុងសេចក្តីប្រកាសនេះ ។ ជាសក្ខីភាព ប្រទេសជាដៃគូមួយចំនួនបានបង្ហាញនូវផែនការសកម្មភាពរបស់ខ្លួន ហើយអ្នកផ្តល់ជំនួយក៏បានប្រកាសនូវការប្តេជ្ញាចិត្តថ្មីៗដែលមានសារៈសំខាន់ជាច្រើន ។ យើងសូមស្នើភាគីទាំងអស់ដែលមានបំណងផ្តល់ពត៌មានបន្ថែមលើគំនិតផ្តួចផ្តើមទាំងនេះ សូមផ្ញើមកអោយយើងអោយបានត្រឹមថ្ងៃទី៤ ខែមេសា ឆ្នាំ២០០៥ សំរាប់ការបោះពុម្ពលើកបន្ទាប់ ។

## **តាមដាននិងវាយតំលៃការអនុវត្តន៍**

១០. ដោយហេតុថាការសំរេចអោយបាននូវវឌ្ឍនភាពក្នុងកំរិតប្រទេសជាប្រការមានសារៈសំខាន់ យើងនឹងធ្វើការវាយតំលៃជាប្រចាំលើគ្រប់ជ្រុងជ្រោយ នូវវឌ្ឍនភាពរួមគ្នារបស់យើងនៅកំរិតប្រទេស ក្រោមការដឹកនាំរបស់ប្រទេសជាដៃគូ ។ យើងនឹងប្រើប្រាស់យន្តការរបស់ប្រទេសជាដៃគូ ក្នុងករណីសមស្របដើម្បីធ្វើការងារនេះ ។

១១. នៅកំរិតអន្តរជាតិ យើងអំពាវនាវអោយភាពជាដៃគូរវាងម្ចាស់ជំនួយនិងប្រទេសជាដៃគូ ដែលរៀបចំដោយគណៈកម្មាធិការជំនួយអភិវឌ្ឍន៍ ពង្រីកការចូលរួមពីសំណាក់ប្រទេសជាដៃគូបន្ថែមទៀត ត្រឹមដំណាច់ឆ្នាំ២០០៥ និងរៀបចំយន្តការសំរាប់ការតាមដានការអនុវត្តន៍ការប្តេជ្ញាចិត្តនៅក្នុងសេចក្តីប្រកាសនេះ សំរាប់រយៈពេលមធ្យមមួយ ។ យើងសូមស្នើផងដែរអោយភាពជាដៃគូ ដែលរៀបចំដោយគណៈកម្មាធិការជំនួយអភិវឌ្ឍន៍ ធ្វើការសំរបសំរួលការតាមដាននៅកំរិតអន្តរជាតិ ការអនុវត្តន៍សូចនាករដែលមាននៅក្នុងចំណុចទី៣ ធ្វើការកែសំរួលនូវគោលដៅប្រសិនបើចាំបាច់ ផ្តល់ការណែនាំសំរាប់កំណត់ចំណុចចាប់ផ្តើម និងដាក់បញ្ចូលពត៌មានដែលប្រមូលបានពីប្រភពផ្សេងៗគ្នាអោយមានសង្គតិភាពសំរាប់ការរៀបចំរបាយការណ៍ ។ យើងនឹងប្រើប្រាស់នូវយន្តការត្រួតពិនិត្យដែលមានស្រាប់ និងយន្តការនៅតាមថ្នាក់តំបន់ ដើម្បីគាំទ្រការអនុវត្តន៍គោលដៅទាំងនេះ ។ យើងនឹងពិនិត្យមើលពីយន្តការតាមដាននិងវាយតំលៃ នៅកំរិតប្រទេសផងដែរ ដើម្បីយល់ដឹងអោយកាន់តែទូលំទូលាយថែមទៀត នូវឥទ្ធិពលរបស់ជំនួយក្នុងការចូលរួមក្នុងកិច្ចអភិវឌ្ឍន៍ ដោយមិនដាក់បន្ទុកបន្ថែមលើប្រទេសជាដៃគូទៀតឡើយ ។

១២. យើងមានផែនការដើម្បីជួបប្រជុំគ្នាម្តងទៀតនៅក្នុងឆ្នាំ២០០៨ នៅក្នុងប្រទេសជាដៃគូណាមួយ ដើម្បីធ្វើការតាមដានពីរដងជាមុនសិន មុននឹងពិនិត្យឡើងវិញនូវវឌ្ឍនភាពក្នុងការអនុវត្តន៍សេចក្តីប្រកាសនេះ ។

## ២.ការប្តេជ្ញាក្នុងការកសាងភាពជាដៃគូ

១៣. ដោយតាក់តែងឡើងក្នុងស្មារតីទទួលខុសត្រូវទៅវិញទៅមក ការប្តេជ្ញាខាងក្រោមនេះបានមកពីមេរៀននៃបទពិសោធន៍ដែលយើងបានទទួល ។ យើងទទួលស្គាល់ថាការប្តេជ្ញាទាមទារអោយមានការបកស្រាយសមស្របតាមស្ថានភាពជាក់ស្តែងរបស់ប្រទេសជាដៃគូនីមួយៗ ។

### ភាពជាម្ចាស់

ប្រទេសជាដៃគូជាអ្នកដឹកនាំលើគោលនយោបាយនិងយុទ្ធសាស្រ្តអភិវឌ្ឍន៍ និងសំរបសំរួលសកម្មភាពទាំងនោះ

១៤ . ប្រទេសជាដៃគូប្តេជ្ញាដូចខាងក្រោម ÷

- មានតួនាទីជាអ្នកដឹកនាំក្នុងការអភិវឌ្ឍន៍និងអនុវត្តន៍យុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ តាមដំណើរការពិគ្រោះយោបល់ដោយទូលំទូលាយ ។
- ប្រែក្លាយយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិអោយក្លាយជាកម្មវិធីសកម្មភាពដែលមានលទ្ធផលរំពឹងជាក់លាក់ និងមានអាទិភាព ក្នុងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងថវិកាជាតិ ។
- ដឹកនាំការសំរបសំរួលជំនួយនៅគ្រប់កំរិត ដោយពិគ្រោះជាមួយអ្នកផ្តល់ជំនួយ និងដោយមានការចូលរួមពីសំណាក់សង្គមស៊ីវិល និងវិស័យឯកជន ។

១៥ . អ្នកផ្តល់ជំនួយប្តេជ្ញាថាដូចខាងក្រោម ÷

- គោរពភាពជាអ្នកដឹកនាំរបស់ប្រទេសជាដៃគូ និងគាំទ្រការពង្រឹងសមត្ថភាព ។

### ការសំរបសំរួលជំនួយ

*អ្នកផ្តល់ជំនួយតំរែតំរង់ការគាំទ្ររបស់ពួកគេជាមួយយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ*
*ស្ថាប័ន និងនីតិវិធីរបស់ប្រទេសជាដៃគូ*

### អ្នកផ្តល់ជំនួយសំរបការផ្តល់ជំនួយជាមួយយុទ្ធសាស្រ្តប្រទេសជាដៃគូ

១៦. អ្នកផ្តល់ជំនួយប្តេជ្ញាដូចខាងក្រោម ÷

- ផ្តល់កិច្ចគាំទ្ររបស់ពួកគេផ្អែកលើយុទ្ធសាស្រ្ត គោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍របស់ប្រទេសជាដៃគូ និងពិនិត្យជាប្រចាំការអនុវត្តន៍យុទ្ធសាស្រ្តទាំងនេះ (សូចនាករទី៣) ។
- ដាក់លក្ខខ័ណ្ឌដែលបានមកពីយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិរបស់ប្រទេសជាដៃគូ ឬការពិនិត្យដំណើរការអនុវត្តន៍ប្រចាំឆ្នាំ ។ លក្ខខ័ណ្ឌផ្សេងទៀតអាចត្រូវបានយកមកប្រើ ដោយឈរលើមូលដ្ឋានយុត្តិកម្ម

ត្រឹមត្រូវប៉ុណ្ណោះ ប្រកបដោយតំលាភាព និងដោយមានការពិភាក្សា ជាមួយនិងអ្នកផ្តល់ជំនួយពាក់ព័ន្ធ ។

- ភ្ជាប់ហិរញ្ញប្បទានទៅនឹងលក្ខខ័ណ្ឌឬសូចនាករដែលមានក្របខ័ណ្ឌតែមួយ និងដែលអាចអនុវត្តទៅបាន ដោយប្រើប្រាស់យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ប្រការនេះមិនមែនមានន័យថា គ្រប់អ្នកផ្តល់ជំនួយទាំងអស់មានលក្ខខ័ណ្ឌដូចៗគ្នានោះទេ ប៉ុន្តែលក្ខខ័ណ្ឌរបស់អ្នកផ្តល់ជំនួយ គួរតែជាលក្ខខ័ណ្ឌដែលចេញមកពីក្របខ័ណ្ឌទូទៅមួយ សំដៅសំរេចអោយបាននូវគោលដៅដែលមាន ។

## អ្នកផ្តល់ជំនួយប្រើប្រាស់ប្រព័ន្ធរបស់ប្រទេសជាដៃគូ

១៧. ការប្រើប្រាស់ស្ថាប័ននិងប្រព័ន្ធរបស់ប្រទេសជាដៃគូ នៅពេលដែលមានការធានាថាជំនួយនឹងត្រូវបានប្រើប្រាស់សំរាប់គោលបំណងដែលបានព្រមព្រៀងគ្នា នឹងបង្កើនប្រសិទ្ធភាពជំនួយ តាមរយៈការពង្រឹងសមត្ថភាពរបស់ប្រទេសជាដៃគូក្នុងការការអភិវឌ្ឍន៍ ការអនុវត្តន៍ និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ ។ ជាទូទៅ ប្រព័ន្ធនិងនីតិវិធីរបស់ប្រទេសជាដៃគូ មានដូចជាបែបបទគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការងារគណនេយ្យ សវនកម្ម លទ្ធកម្ម និងការតាមដានលទ្ធផល ។

១៨. ការសិក្សាវិភាគវិនិច្ឆ័យជាប្រភពពត៌មានដែលមានលក្ខណៈសំខាន់សំរាប់រដ្ឋាភិបាល និងអ្នកផ្តល់ជំនួយស្តីពីស្ថានភាពនៃប្រព័ន្ធ និងស្ថាប័នរបស់ប្រទេសជាដៃគូ ។ ប្រទេសជាដៃគូនិងអ្នកផ្តល់ជំនួយមានបុព្វហេតុរួមក្នុងការតាមដានវឌ្ឍនភាព ក្នុងការធ្វើអោយប្រសើរឡើងនូវប្រព័ន្ធរបស់ប្រទេសជាដៃគូ ។ ក្របខ័ណ្ឌសំរាប់ធ្វើការវាយតំលៃសកម្មភាព និងវិធានការណ៍មួយចំនួនទៀត សុទ្ធតែមានសារៈសំខាន់ ហើយដែលត្រូវពឹងផ្អែកលើការសិក្សាវិភាគវិនិច្ឆ័យដែលមាន ។

១៩. ប្រទេសជាដៃគូនិងអ្នកផ្តល់ជំនួយរួមគ្នាប្តេជ្ញាដូចខាងក្រោម ÷

- សហការគ្នាបង្កើតក្របខ័ណ្ឌរួមមួយ ដែលអាចផ្តល់ការវាយតំលៃពីកំរិតនៃការអនុវត្តន៍ តម្លាភាព និងគណនេយ្យភាពនៃប្រព័ន្ធរបស់ប្រទេសជាដៃគូ (សូចនាករទី២) ។
- បញ្ចូលការសិក្សាវិភាគ និងក្របខ័ណ្ឌវាយតំលៃសកម្មភាព ទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាព របស់ប្រទេសជាដៃគូ ។

២០. ប្រទេសជាដៃគូប្តេជ្ញាដូចខាងក្រោម ÷

- ធ្វើការសិក្សាវិភាគដែលអាចជឿទុកចិត្តបាន ស្តីពីប្រព័ន្ធនិងនីតិវិធីរបស់ជាតិ ។
- ឈរលើមូលដ្ឋាននៃការសិក្សាទាំងនេះ ធ្វើការកែទំរង់ប្រព័ន្ធរបស់ជាតិ ដើម្បីអោយមានប្រសិទ្ធភាព គណនេយ្យភាព និងតំលាភាព ។
- ធើការកែទំរង់ការ ដូចជាកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាកត្តាចាំបាច់សំរាប់ការចាប់ផ្តើម និងទ្រទ្រង់ដំណើរការអភិវឌ្ឍន៍សមត្ថភាព។

២១. អ្នកផ្តល់ជំនួយប្តេជ្ញាដូចខាងក្រោម ÷

- ប្រើប្រាស់ប្រព័ន្ធនិងនិតិវិធីរបស់ប្រទេសជាដៃគូ អោយបានច្រើនបំផុត ។ ក្នុងករណីដែលអ្នកផ្តល់ជំនួយមិនអាចប្រើប្រាស់នូវប្រព័ន្ធរបស់ប្រទេសជាដៃគូបាន អ្នកផ្តល់ជំនួយនឹងអនុវត្តសកម្មភាពរបស់ខ្លួន ដើម្បីជួយពង្រឹង និងជៀសវាងការធ្វើអោយអន្តរាយដល់ប្រព័ន្ធនិងនិតិវិធីរបស់ប្រទេសជាដៃគូ (សូចនាករទី៥) ។
- ជៀសវាងអោយបាន ការបង្កើតរចនាសម្ព័ន្ធមួយដែលរឹងមាំ សំរាប់ដំណើរការគ្រប់គ្រងគំរោងប្រចាំថ្ងៃ (សូចនាករទី៦) ។
- បង្កើតក្របខ័ណ្ឌសំរាប់ធ្វើការវាយតំលៃមួយដែលមានសុខដុមនីយកម្មជាមួយប្រទេសជាដៃគូ ដើម្បីជៀសវាងភាពស្មុគ្រស្មាញដែលបណ្តាលមកពីគោលដៅរបស់ក្របខ័ណ្ឌទាំងនេះ ។

**ប្រទេសជាដៃគូពង្រឹងការអភិវឌ្ឍន៍សមត្ថភាពដោយមានការគាំទ្រពីអ្នកផ្តល់ជំនួយ**

២២. សមត្ថភាពក្នុងផ្នែករៀបចំផែនការ ការគ្រប់គ្រង ការអនុវត្តន៍ និងការទទួលខុសត្រូវលើលទ្ធផលនៃការអនុវត្តន៍គោលនយោបាយនិងកម្មវិធី ជាកត្តាដែលមានសារៈសំខាន់ដល់ការសំរេចអោយបាន គោលដៅនៃការអភិវឌ្ឍន៍ ដោយចាប់ផ្តើមពីការវិភាគ និងពិគ្រោះយោបល់ ដល់ការអនុវត្តន៍ រួមជាមួយការតាមដាននិងវាយតំលៃ ។ ការអភិវឌ្ឍន៍សមត្ថភាពគឺជាការទទួលខុសត្រូវរបស់ប្រទេសជាដៃគូ ដោយអ្នកផ្តល់ជំនួយមានតួនាទីជាអ្នកគាំទ្រ ។ វាមិនគ្រាន់តែជាសមត្ថភាពក្នុងការធ្វើវិភាគបែបបច្ចេកទេសតែមួយមុខនោះទេ ប៉ុន្តែថែមទាំងជាលទ្ធភាពក្នុងការឆ្លើយតបនឹងបរិយាកាសសង្គម សេដ្ឋកិច្ច និងនយោបាយ រួមទាំងការពង្រឹងធនធានមនុស្សផងដែរ ។

២៣. ប្រទេសជាដៃគូប្តេជ្ញាដូចតទៅ ÷

- បញ្ចូលគោលដៅនៃការពង្រឹងសមត្ថភាពទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងអនុវត្តនូវយុទ្ធសាស្ត្រទាំងនេះ ។

២៤. អ្នកផ្តល់ជំនួយប្តេជ្ញាដូចតទៅ ÷

- តំរែតំរង់ការគាំទ្រជាមួយនឹងគោលដៅ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍សមត្ថភាពរបស់ប្រទេសជាដៃគូ និងប្រើប្រាស់សមត្ថភាពដែលមានស្រាប់ ព្រមទាំងធ្វើសុខដុមនីយកម្ម (សូជនាករទី ៤) ។

**ពង្រឹងសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

២៥. បណ្តាប្រទេសជាដៃគូប្តេជ្ញាដូចតទៅ ÷

- បង្កើនកិច្ចប្រឹងប្រែងប្រមែប្រមូលធនធាននៅក្នុងស្រុក ពង្រឹងនិរន្តរភាពសារពើពន្ធ និងបង្កើតបរិយាកាសមួយដែលអំណោយផលសំរាប់វិនិយោគសាធារណៈនិងឯកជន ។

- ផ្សព្វផ្សាយអោយទាន់ពេលវេលា របាយការណ៍ស្តីពីការប្រើប្រាស់ថវិកា ។
- ដឹកនាំដំណើរការកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

២៦. អ្នកផ្តល់ជំនួយប្តេជ្ញាដូចតទៅ ÷
- ធ្វើការសន្យាផ្តល់ជំនួយក្នុងក្របខ័ណ្ឌច្រើនឆ្នាំ និងផ្តល់ជំនួយក្នុងលក្ខណៈអាចប៉ាន់ស្មានបាន និងតាមពេលវេលាដែលបានឯកភាពគ្នា (សូចនាករទី៧) ។
- អនុលោមតាមថវិការបស់រដ្ឋាភិបាលអោយបានច្រើនបំផុត និងប្រើប្រាស់យន្តការគណនេយ្យរបស់ប្រទេសជាដៃគូ (សូចនាករទី ៥) ។

២៧. ប្រទេសជាដៃគូនិងអ្នកផ្តល់ជំនួយប្តេជ្ញាដូចខាងក្រោម ÷
- ធ្វើការសិក្សាវិភាគ និងអនុវត្តក្របខ័ណ្ឌសំរាប់ការវាយតំលៃអោយបានប្រកបដោយសុខដុមនីយកម្ម ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

**ពង្រឹងប្រព័ន្ធលទ្ធកម្មជាតិ**

២៨. ប្រទេសជាដៃគូនិងអ្នកផ្តល់ជំនួយប្តេជ្ញាដូចតទៅ ÷
- ប្រើប្រាស់បទដ្ឋាននិងដំណើរដែលបានឯកភាពគ្នា សំរាប់ការធ្វើការសិក្សាវិភាគ រៀបចំកម្មវិធីកំណែទំរង់ និងតាមដានការអនុវត្តន៍ ។
- ផ្តល់ធនធានគ្រប់គ្រាន់ដើម្បីគាំទ្រកំណែទំរង់លទ្ធកម្មសាធារណៈ សំរាប់រយៈពេលវែងនិងមធ្យម និងការអភិវឌ្ឍន៍សមត្ថភាព ។
- ចែករំលែកយោបល់នៅថ្នាក់ប្រទេស ដើម្បីធ្វើការកែលំអ ។

២៩. ប្រទេសជាដៃគូសន្យាប្តេជ្ញាធ្វើជាអ្នកដឹកនាំ និងអនុវត្តកំណែទំរង់លទ្ធកម្មសាធារណៈ ។

៣០. អ្នកផ្តល់ជំនួយប្តេជ្ញាដូចខាងក្រោម ÷
- ប្រើប្រាស់ជាបណ្តើរៗ នូវប្រព័ន្ធរបស់ប្រទេសជាដៃគូ សំរាប់ការងារលទ្ធកម្ម នៅពេលដែលប្រទេសជាដៃគូបានអនុវត្តដំណើរការកែទំរង់ដែលបានឯកភាពគ្នា (សូចនាករទី ៥) ។
- ធ្វើសុខដុមនីយកម្ម នៅពេលដែលប្រព័ន្ធរបស់ប្រទេសជាដៃគូមិនទាន់អាចឈានដល់កំរិតឯកភាពដែលអាចអនុវត្តសកម្មភាព ។

**លុបបំបាត់លក្ខខ័ណ្ឌសំរាប់ជំនួយ : បង្កើនតំលៃរបស់ជំនួយ**

៣១. លុបបំបាត់នូវលក្ខខ័ណ្ឌដែលភ្ជាប់ជំនួយនឹងបង្កើនប្រសិទ្ធភាពជំនួយ ដោយការកាត់បន្ថយចំណាយប្រតិបត្តិការសំរាប់ប្រទេសជាដៃគូ និងជំរុញភាពជាម្ចាស់ និងការតំរែតំរង់ជំនួយ ។ អ្នកផ្តល់ជំនួយដែលជា

សមាជិកគណៈកម្មាធិការជំនួយអភិវឌ្ឍន៍នឹងបន្តការលុបបំបាត់លក្ខខ័ណ្ឌចងភ្ជាប់ជំនួយ ដូចមាននៅក្នុង អនុសាសន៍របស់គណៈកម្មាធិការជំនួយអភិវឌ្ឍន៍ នៅឆ្នាំ២០០១ ស្តីពីការលុបបំបាត់លក្ខខ័ណ្ឌភ្ជាប់ជំនួយ អភិវឌ្ឍន៍ផ្លូវការទៅដល់បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចបំផុត (សូចនាករទី៨) ។

## **សុខដុមនីយកម្ម**

*អ្នកផ្តល់ជំនួយធ្វើសុខដុមនីយកម្មសកម្មភាព មានតំលាភាព និងដែលមានភាព និងប្រសិទ្ធភាព*

### **អ្នកផ្តល់ជំនួយអនុវត្តទំរង់ការរួម និងធ្វើអោយមានភាពសាមញ្ញនូវនីតិវិធីផ្តល់ជំនួយ**

៣២. អ្នកផ្តល់ជំនួយប្តេជ្ញាដូចតទៅ ÷

- អនុវត្តផែនការសកម្មភាពដែលបានរៀបចំឡើង ជាផ្នែកមួយនៃការតាមដានបន្ទាប់ពីវេទិកាកំរិតខ្ពស់ ទីក្រុងរ៉ូម ។
- អនុវត្តនៅថ្នាក់ប្រទេស ទំរង់ការរួមក្នុងការធ្វើផែនការ ការធ្វើហិរញ្ញប្បទាន (ដូចជាការរៀបចំថវិកា រួមគ្នា) ការផ្តល់ជំនួយ ការតាមដាន ការវាយតំលៃ និងការធ្វើរបាយការណ៍ ស្តីពីសកម្មភាព និង លំហូរជំនួយ ។ ការបង្កើនការប្រើប្រាស់បែបបទផ្តល់ជំនួយតាមកម្មវិធីអាចចូលរួមដល់កិច្ចខិតខំ ទាំងនេះ (សូចនាករទី៩) ។
- សហការគ្នាបន្ថយនូវចំនួនបេសកកម្ម ដែលមានចំនួនច្រើននិងជាន់គ្នា និងចំនួននៃការសិក្សាវិភាគ (សូចនាករទី១០) ព្រមទាំងជំរុញការបណ្តុះបណ្តាលរួមគ្នាដើម្បីចែករំលែកមេរៀនដែលទទួលបាន និង កសាងសហគមន៍នៃការអនុវត្តន៍រួមមួយ ។

### **ការបំពេញនៅវិញនៅមក : បំណែងចែកពលកម្មដែលមានប្រសិទ្ធភាពជាងមុន**

៣៣. ការផ្តល់ជំនួយដែលមានលក្ខណៈដាច់ដោយឡែកៗច្រើនហួសប្រមាណនៅលើពិភពលោក នៅតាម វិស័យ ឬនៅកំរិតប្រទេស ធ្វើអោយថមថយប្រសិទ្ធភាពជំនួយ ។ អភិក្រមដែលមានលក្ខណៈទន់ភ្លន់ ដល់ការបែងចែកពលកម្ម និងរួមគ្នាទទួលចំណាច អាចបង្កើននូវការបំពេញអោយគ្នាទៅវិញទៅមក និងបន្ថយចំណាយប្រតិបត្តិការ ។

៣៤. ប្រទេសជាដៃគូប្តេជ្ញាដូចតទៅ ÷

- ផ្តល់រូបភាពច្បាស់លាស់ពីឧត្តមភាពប្រៀបធៀបរបស់អ្នកផ្តល់ជំនួយ និងមធ្យោបាយសំរេចអោយបាន ការបំពេញអោយគ្នាទៅវិញទៅមកនៅក្នុងប្រទេសឬតាមវិស័យ ។

៣៥. អ្នកផ្តល់ជំនួយប្តេជ្ញាដូចតទៅ ÷

- ប្រើប្រាស់អោយបានពេញលេញឧត្តមភាពប្រៀបធៀបនៅថ្នាក់ប្រទេសឬតាមវិស័យដោយធ្វើប្រតិភូកម្ម សិទ្ធិសំរេចអោយអ្នកផ្តល់ជំនួយចំបងក្នុងការអនុវត្តន៍កម្មវិធី និងសកម្មភាព ។

- សហការគ្នាដើម្បីធ្វើសុខដុមនីយកម្ម ។

## ការលើកទឹកចិត្តសំរាប់ការរួមសហការគ្នា

៣៦. ប្រទេសអ្នកផ្តល់ជំនួយនិងប្រទេសជាដៃគូប្តេជ្ញាដូចខាងក្រោម ÷

- កែទំរង់បែបបទនិងពង្រឹងការលើកទឹកចិត្ត ដែលរួមមានការជ្រើសរើសបុគ្គលិក ការវាយតំលៃ និងការបណ្តុះបណ្តាល ដល់បុគ្គលិកដែលបំរើការក្នុងការងារសុខដុមនីយកម្ម ។

## ការផ្តល់ជំនួយមានប្រសិទ្ធភាពអោយរដ្ឋដែលរងវិបត្តិ

៣៧. ទស្សនៈវិស័យទៅអនាគតយូរអង្វែង ក្នុងទំនាក់ទំនងអន្តរជាតិសំរាប់រដ្ឋដែលទទួលរងវិបត្តិ គឺការកសាងនូវក្បាលម៉ាស៊ីនដឹកនាំរដ្ឋ និងស្ថាប័នចាំបាច់ដទៃទៀត ដែលមានធម្មនុញ្ញភាព មានប្រសិទ្ធភាព និងរឹងប៉ឹង ។ បើទោះបីជាគោលការណ៍នៃការផ្តល់ជំនួយប្រកបដោយប្រសិទ្ធភាព ក៏ត្រូវអនុវត្តដូចគ្នាសំរាប់បណ្តារដ្ឋដែលទទួលរងវិបត្តិក៏ដោយ មានការចាំបាច់ដែលត្រូវតែធ្វើការសំរបសំរួលទៅនឹងបរិយាកាសនៃការគ្រប់គ្រង និងសមត្ថភាពទន់ខ្សោយ ព្រមទាំងសេចក្តីត្រូវការចំពោះមុខ និងការផ្តល់សេវាជាមូលដ្ឋានផងដែរ ។

៣៨. ប្រទេសជាដៃគូប្តេជ្ញាដូចតទៅ ÷

- ខិតខំសំរេចអោយបាននូវវឌ្ឍនភាពសំដៅកសាងស្ថាប័ន និងរចនាសម្ព័ន្ធអភិបាលកិច្ច ដែលអាចផ្តល់ការគ្រប់គ្រងដ៏មានប្រសិទ្ធភាព មានសុវត្ថិភាព សន្តិសុខ និងសមធិមសំរាប់ប្រជាពលរដ្ឋ ។
- ចូលរួមពិភាក្សាគ្នាជាមួយអ្នកផ្តល់ជំនួយពីការបង្កើតឧបករណ៍ផែនការកម្មសាមញ្ញៗ ដូចជាម៉ាទ្រីសលទ្ធផលអន្តរកាល នៅពេលដែលយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិមិនទាន់មាននៅឡើយ ។
- ជំរុញអោយមានការចូលរួមអោយបានច្រើនពីគ្រប់ភាគីក្នុងការរៀបចំអាទិភាពអភិវឌ្ឍន៍ ។

៣៩. អ្នកផ្តល់ជំនួយប្តេជ្ញាដូចខាងក្រោម ÷

- ធ្វើសុខដុមនីយកម្មសកម្មភាពរបស់ខ្លួន ។ សុខដុមនីយកម្មមានសារៈសំខាន់ នៅពេលដែលភាពជាអ្នកដឹកនាំរបស់ប្រទេសជាដៃគូនៅមានកំរិតនៅឡើយ ។ សុខដុមនីយកម្មគួរផ្តោតទៅលើការវិភាគការវាយតំលៃរួម ការកសាងយុទ្ធសាស្ត្ររួម ការសំរបសំរួលផ្នែកនយោបាយ និងគំនិតផ្តួចផ្តើមសាមញ្ញៗ ដូចជាការបង្កើតនូវការិយាល័យរួមមួយរបស់អ្នកផ្តល់ជំនួយ ។
- តំរែតំរង់ជំនួយអោយបានច្រើនបំផុត ជាមួយយុទ្ធសាស្ត្ររបស់ប្រទេសជាដៃគូ ឬប្រសិនបើមិនអាចធ្វើទៅបាន អ្នកផ្តល់ជំនួយទាំងអស់គួរប្រើប្រាស់ប្រព័ន្ធរបស់ប្រទេសជាដៃគូ ។
- ជៀសវាងសកម្មភាពដែលជាឧបសគ្គដល់ការកសាងស្ថាប័នរបស់ប្រទេសជាដៃគូ ដូចជាការមិនប្រើប្រាស់នូវដំណើរការថវិការបស់ប្រទេសជាដៃគូ ឬការអោយបៀវត្សរ៍ខ្ពស់កប់ពពកដល់មន្ត្រីដែលបំរើការក្នុងប្រទេសជាដៃគូ ។

- ប្រើប្រាស់ឧបករណ៍ផ្តល់ជំនួយផ្សេងៗគ្នា ដូចជាការគាំទ្រការផ្តល់ហិរញ្ញប្បទាន ជាពិសេសសំរាប់ប្រទេសដែលមានស្ថានភាពហានិភ័យខ្ពស់ ។

## សុខដុមនីយកម្មការវាយតំលៃផ្នែកបរិស្ថាន

៤០. អ្នកផ្តល់ជំនួយសំរេចបានវឌ្ឍនភាពគួរអោយកត់សំគាល់ ក្នុងការធ្វើសុខដុមនីយកម្ម ជុំវិញការវាយតំលៃផលប៉ះពាល់ផ្នែកបរិស្ថាន ដូចជាបញ្ហាពាក់ព័ន្ធនឹងសុខភាពនិងសង្គម នៅពេលអនុវត្តន៍គំរោងរបស់ខ្លួន ។ វឌ្ឍនភាពនេះចាំបាច់ត្រូវធ្វើអោយកាន់តែមានលក្ខណៈស៊ីជម្រៅបន្ថែមទៀត ដោយរួមបញ្ចូលការដោះស្រាយបញ្ហាបរិស្ថានជាសកល ដូចជាការផ្លាស់ប្តូរសីតុណ្ហភាព ភាពហួតហែង និងការបាត់បង់ជីវចំរុះ ។

៤១. អ្នកផ្តល់ជំនួយ និងប្រទេសជាដៃគូប្តេជ្ញាដូចតទៅ ÷
- ពង្រឹងការអនុវត្តន៍ការតាមដានផលប៉ះពាល់ផ្នែកបរិស្ថាន និងពង្រឹងនីតិវិធីរួមសំរាប់ការអនុវត្តន៍គំរោង រួមទាំងការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងបង្កើតនិងអនុវត្តអភិក្រមរួមស្តីពីយុទ្ធសាស្រ្តតាមដានផលប៉ះពាល់ផ្នែកបរិស្ថាន នៅតាមថ្នាក់ជាតិ និងតាមវិស័យ ។
- បន្តពង្រឹងសមត្ថភាពផ្នែកគោលនយោបាយ និងផ្នែកបច្ចេកទេស ចាំបាច់សំរាប់ការវិភាគលើផលប៉ះពាល់បរិស្ថាន និងសំរាប់ការពង្រឹងប្រព័ន្ធច្បាប់ និងនីតិវិធី ។

៤២. កិច្ចប្រឹងប្រែងធ្វើសុខដុមនីយកម្ម គឺចាំបាច់ផងដែរចំពោះបញ្ហាពហុវិស័យមួយចំនួនទៀត ដូចជាសមភាពយេនឌ័រ និងបញ្ហាដែលទទួលហិរញ្ញប្បទានធំធេង ។

## គ្រប់គ្រងដើម្បីលទ្ធផល

*គ្រប់គ្រងធនធាន និងការកែលំអសេចក្តីសំរេចដើម្បីលទ្ធផល*

៤៣. ការគ្រប់គ្រងដើម្បីលទ្ធផលមានន័យថាគ្រប់គ្រង និងអនុវត្តការផ្តល់ជំនួយ តាមមធ្យោបាយមួយ ដែលផ្តោតលើលទ្ធផលដែលរំពឹងទុក និងប្រើប្រាស់ពត៌មានដើម្បីធ្វើការសំរេចចិត្ត ។

៤៤. ប្រទេសជាដៃគូប្តេជ្ញាដូចខាងក្រោម ÷
- ពង្រឹងទំនាក់ទំនងរវាងយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងដំណើរការរៀបចំថវិកាប្រចាំឆ្នាំ និងច្រើនឆ្នាំ ។
- ប្រឹងប្រែងរៀបចំក្របខ័ណ្ឌសំរាប់ការតាមដាននិងវាយតំលៃផ្នែកលើលទ្ធផល ដែលអាចត្រួតពិនិត្យវឌ្ឍនភាពនៃសូចនាករនៅក្នុងយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិនិងតាមវិស័យ ។ ក្របខ័ណ្ឌទាំងនេះគួរតាមដានពីចំនួនសូចនាករដែលអាចធ្វើបាន ហើយដែលមានទិន្នន័យស្រាប់ (សូចនាករទី១១) ។

៤៥. អ្នកផ្តល់ជំនួយប្តេជ្ញាថា ÷

- ភ្ជាប់កម្មវិធីជំនួយសំរាប់ប្រទេសនិងធនធានទៅនឹងលទ្ធផល ហើយត៏រឹមកម្មវិធីនិងធនធានទាំងនោះជាមួយក្របខ័ណ្ឌតាមដានការអនុវត្តន៍របស់ប្រទេសជាដៃគូ ដោយជៀសវាងបញ្ចូលសូចនាករថ្មីដែលមិនមានសង្គតភាពជាមួយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់ប្រទេសជាដៃគូ ។
- ធ្វើការងារជាមួយប្រទេសដៃគូ ដោយប្រើប្រាស់ក្របខ័ណ្ឌសំរាប់តាមដាន និងរាយការណ៍របស់ប្រទេសជាដៃគូ ។
- ធ្វើសុខដុមនីយកម្មការធ្វើរបាយការណ៍និងត្រួតពិនិត្យជាមួយប្រព័ន្ធរបស់ប្រទេសជាដៃគូ រហូតដល់ប្រទេសជាដៃគូមានប្រព័ន្ធស្ថិតិ ត្រួតពិនិត្យនិងវាយតំលៃរបស់ខ្លួនដែលអាចប្រើប្រាស់បាន និងរៀបចំទំរង់រួមសំរាប់ការធ្វើរបាយការណ៍ ។

៤៦. ប្រទេសដៃគូ និងអ្នកផ្តល់ជំនួយប្តេជ្ញារួមគ្នាដូចតទៅ÷

- ធ្វើការងាររួមគ្នាដោយមានការចូលរួមដើម្បីកសាងសមត្ថភាពប្រទេសជាដៃគូ និងដើម្បីលទ្ធផល ។

## គណនេយ្យភាពទៅវិញទៅមក

*អ្នកផ្តល់ជំនួយ និងប្រទេសជាដៃគូទទួលខុសត្រូវរួមគ្នាលើលទ្ធផល*

៤៧. អាទិភាពចំបងសំរាប់ប្រទេសជាដៃគូនិងអ្នកផ្តល់ជំនួយ គឺត្រូវពង្រឹងគណនេយ្យភាព និងតម្លាភាពទៅវិញទៅមកក្នុងការប្រើប្រាស់ធនធានអភិវឌ្ឍន៍ ។ ប្រការនេះជួយពង្រឹងផងដែរនូវការគាំទ្រជាសាធារណៈលើគោលនយោបាយជាតិ និងជំនួយអភិវឌ្ឍន៍ ។

៤៨. ប្រទេសដៃគូប្តេជ្ញាដូចតទៅ÷

- ពង្រឹងតួនាទីរបស់ស្ថាប័ននីតិបញ្ញត្តិ ក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងថវិកា ។
- ពង្រឹងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការរៀបចំ និងតាមដានវឌ្ឍភាពនៃការអនុវត្តន៍យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

៤៩. អ្នកផ្តល់ជំនួយប្តេជ្ញាដូចខាងក្រោម÷

- ផ្តល់ពត៌មានត្រឹមត្រូវ ទូលំទូលាយ និងទាន់ពេលវេលា ស្តីពីលំហូរជំនួយ ដែលអាចអោយប្រទេសជាដៃគូ រៀបចំរបាយការណ៍ថវិកាសំរាប់បង្ហាញប្រជាពលរដ្ឋ និងសភា ។

៥០. ប្រទេសដៃគូ និងអ្នកផ្តល់ជំនួយប្តេជ្ញាដូចតទៅ÷

- ធ្វើការតាមដានវឌ្ឍនភាពរួមគ្នា ដោយប្រើប្រាស់យន្តការប្រទេសជាដៃគូដែលមានស្រាប់ ក្នុងការអនុវត្តន៍ការប្តេជ្ញាចិត្តដែលបានព្រមព្រៀងស្តីពីប្រសិទ្ធភាពជំនួយ រួមទាំងការប្តេជ្ញាចិត្ត ស្តីពីការកសាងភាពជាដៃគូ (សូចនាករទី១២) ។

## សូចនាករវឌ្ឍនភាព

*វាស់ស្ទង់នៅកម្រិតជាតិ និងត្រួតពិនិត្យក្នុងកម្រិតអន្តរជាតិ*

| | ភាពជាម្ចាស់ | ទិសដៅសំរាប់ឆ្នាំ ២០១០ |
|---|---|---|
| ១ | ប្រទេសជាដៃគូមានយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ : ចំនួនប្រទេស និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (រួមទាំងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ) ដែលមានអាទិភាពយុទ្ធសាស្ត្រច្បាស់លាស់ តភ្ជាប់ទៅនឹងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងឆ្លុះបញ្ចាំងពីថវិកាប្រចាំឆ្នាំ | យ៉ាងតិច ៧៥%* នៃប្រទេសជាដៃគូ |
| | **តម្រឹម** | **ទិសដៅសំរាប់ឆ្នាំ ២០១០** |
| ២ | ប្រព័ន្ធប្រទេសជាដៃគូដែលអាចប្រើប្រាស់បាន : ចំនួនប្រទេសដៃគូដែលមានប្រព័ន្ធលទ្ធកម្ម និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែល (១) មានការអនុវត្តន៍ល្អ ឬ (២) មានកម្មវិធីកំណែទំរង់ | ទិសដៅនឹងត្រូវកំណត់ត្រឹមខែកញ្ញា ឆ្នាំ២០០៥ |
| ៣ | ជំនួយតំរែតំរង់ជាមួយអាទិភាពជាតិ : ភាគរយជំនួយដែលបញ្ចូលជាថវិកាជាតិរបស់ប្រទេសជាដៃគូ | ៨៥%* នៃជំនួយបញ្ចូលក្នុងថវិកា |
| ៤ | ពង្រឹងសមត្ថភាពដោយមានការសំរបសំរួល : ភាគរយនៃការគាំទ្ររបស់អ្នកផ្តល់ជំនួយដើម្បីពង្រឹងសមត្ថភាព តាមរយៈកម្មវិធីដែលមានការសំរបសំរួលស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់ប្រទេសជាដៃគូ | ទិសដៅនឹងត្រូវកំណត់ត្រឹមខែកញ្ញា ឆ្នាំ ២០០៥ |
| ៥ | ការប្រើប្រាស់ប្រព័ន្ធប្រទេសដៃគូៈ ភាគរយនៃអ្នកផ្តល់ជំនួយ និងលំហូរជំនួយដែលប្រើប្រាស់ ប្រព័ន្ធលទ្ធកម្ម និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ | |

| | | |
|---|---|---|
| | ប្រទេសដៃគូ ដែលប្រព័ន្ធទាំងនោះមានចរិតជាបទពិសោធន៍ល្អ ឬ មានកម្មវិធីកំណែទំរង់រួចជាស្រេចដើម្បីសំរេចបានគោលដៅ | |
| **៦** | ពង្រឹងសមត្ថភាព ដោយជៀសវាងបង្កើតរចនាសម្ព័ន្ធជាន់គ្នា : ចំនួនការិយាល័យអនុវត្តគំរោងក្នុងប្រទេសជាដៃគូ | ទិសដៅនឹងត្រូវកំណត់ត្រឹមខែកញ្ញា ឆ្នាំ ២០០៥ |
| **៧** | ជំនួយអាចព្យាករណ៍ទុកជាមុន : ភាគរយនៃការផ្ដល់ជំនួយតាមកាលបរិច្ឆេទក្នុងក្របខ័ណ្ឌប្រចាំឆ្នាំ ឬច្រើនឆ្នាំ | យ៉ាងតិច ៧៥%* នៃជំនួយដែលផ្ដល់តាមកាលបរិច្ឆេទ |
| **៨** | ជំនួយគឺគ្មានលក្ខខ័ណ្ឌ : ភាគរយនៃជំនួយទ្វេភាគីដែលគ្មានលក្ខខ័ណ្ឌ | វឌ្ឍនភាពកំពុងបន្ត |
| **សុខដុមនីយកម្ម** | | **ទិសដៅសំរាប់ឆ្នាំ ២០១០** |
| **៩** | ប្រើប្រាស់ទំរង់ការនិងនីតិវិធីរួម : ភាគរយនៃជំនួយបានផ្ដល់តាមរយៈអភិក្រមតាមកម្មវិធី | យ៉ាងតិច ២៥%* |
| **១០** | ការសិក្សាវិភាគរួមគ្នា : ភាគរយនៃបេសកកម្ម និងការសិក្សាវិភាគធ្វើរួមគ្នា | ទិសដៅនឹងត្រូវកំណត់ត្រឹមខែកញ្ញា ឆ្នាំ ២០០៥ |
| **គ្រប់គ្រងដើម្បីលទ្ធផល** | | **ទិសដៅសំរាប់ឆ្នាំ ២០១០** |
| **១១** | ក្របខ័ណ្ឌផ្ដោតលើលទ្ធផល : ចំនួនប្រទេសដែលមានក្របខ័ណ្ឌតាមដានពីការអនុវត្តន៍ដែលត្រឹមត្រូវ និងមានតម្លាភាព ដើម្បីធ្វើការតាមដានវឌ្ឍនភាពទៅនឹង (ក) យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង (ខ) កម្មវិធីតាមវិស័យ | ៧៥%* នៃប្រទេសជាដៃគូ |
| **គណនេយ្យភាពរួម** | | **ទិសដៅសំរាប់ឆ្នាំ ២០១០** |
| **១២** | គណនេយ្យភាពរួម : ចំនួនប្រទេសជាដៃគូ ដែលអនុវត្តការតាមដានរួមគ្នានៃវឌ្ឍនភាព ក្នុងការអនុវត្តន៍ការប្តេជ្ញាចិត្តស្តីពីប្រសិទ្ធភាពជំនួយ រួមទាំងការប្តេជ្ញាដែលមានក្នុងសេចក្តីប្រកាស | ទិសដៅនឹងត្រូវកំណត់ត្រឹមខែកញ្ញា ឆ្នាំ ២០០៥ |

*តួលេខទាំងនេះនិងត្រូវសំរេចឬកែប្រែ នាខែកញ្ញា ឆ្នាំ២០០៥

## ឧបសម្ព័ន្ធ ក
## កំណត់សំគាល់ពីវិធីសាស្ត្រនៃសូចនាករវឌ្ឍនភាព

គោលបំណងនៃភាពជាដៃគូផ្តល់នូវក្របខ័ណ្ឌដែលអាចសំរេចអោយបាននូវគណនេយ្យភាព ដែលមានចែងក្នុងសេចក្តីប្រកាសនៅទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពជំនួយ ។ ក្របខ័ណ្ឌនេះគូសបញ្ជាក់ពីការប្តេជ្ញាចិត្តក្នុងភាពជាដៃគូយ៉ាងច្បាស់លាស់ ដែលបានបង្ហាញក្នុងចំណុចទី២ នៃសេចក្តីប្រកាសនេះ ។

**គោលដៅ** : គោលបំណងនៃភាពជាដៃគូផ្តល់នូវក្របខ័ណ្ឌដែលអាចសំរេចអោយបាននូវគណនេយ្យភាព ដែល មានចែងក្នុងសេចក្តីប្រកាសនៅទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពជំនួយ ។ គឺសំដៅវាស់វែងពីសកម្មភាពជារួមនៅ កំរិតប្រទេសនីមួយៗ ។

**កំរិតប្រទេស និងកំរិតពិភពលោក** : សូចនាករត្រូវបានធ្វើការតាមដាននិងកំណត់ ក្នុងកំរិតប្រទេស ដោយមាន ការសហការស្និតរមួតរវាងប្រទេសដៃគូ និងអ្នកផ្តល់ជំនួយ ។ បន្ទាប់មក តំលៃនៃសូចនាករក្នុងកំរិតប្រទេស នឹងត្រូវបូកសរុបនៅកំរិតតំបន់ ឬកំរិតពិភពលោក ។ ការបូកសរុបនៅកំរិតពិភពលោកនឹងត្រូវបានរៀបចំ ឡើងសំរាប់ប្រទេសដែលរៀបរាប់ខាងក្រោម និងសំរាប់គោលដៅនៃការប្រៀបធៀបទិន្នន័យ និងសំរាប់ប្រទេស ដៃគូដែលមានទិន្នន័យពាក់ព័ន្ធផ្សេងៗទៀត ។

**ការអនុវត្តន៍របស់អ្នកផ្តល់ជំនួយ/ប្រទេសដៃគូ** : សូចនាករនៃវឌ្ឍនភាពក៏ជាគោលដៅសំរាប់តាមដានការអនុវត្តន៍របស់អ្នកផ្តល់ជំនួយនិងប្រទេសជាដៃគូនៅកំរិតប្រទេស កំរិតតំបន់ ឬកំរិតពិភពលោក ។ ក្នុងការវាស់វែងការអនុវត្តន៍របស់អ្នកផ្តល់ជំនួយនីមួយៗ សូចនាករទាំងអស់គួរបានត្រូវអនុវត្តជាមួយនិងភាពបត់បែនក្នុងការទទួលស្គាល់ថាអ្នកផ្តល់ជំនួយមានស្ថាប័នខុសៗគ្នា ។

**ទិសដៅ** : ទិសដៅត្រូវបានកំណត់នៅកំរិតពិភពលោក ។ វឌ្ឍនភាពនៃទិសដៅទាំងនេះ និងត្រូវបានវាស់វែងដោយទិន្នន័យប្រមូលបាននៅកំរិតប្រទេស ។ បន្ថែមលើទិសដៅកំរិតពិភពលោក ប្រទេសដៃគូនិងអ្នកផ្តល់ជំនួយអាចយល់ព្រមព្រៀងលើទិសដៅនៅកំរិតប្រទេស ។

**ចំណុចផ្តើម** : ចំណុចផ្តើមនឹងត្រូវបង្កើតឡើងសំរាប់ឆ្នាំ២០០៥ សំរាប់ក្រុមនៃប្រទេសដែលបានជ្រើសរើស ។ ភាពជាដៃគូនៃអ្នកផ្តល់ជំនួយ និងប្រទេសជាដៃគូដែលបានរៀបចំធ្វើឡើងដោយគណៈកម្មការជំនួយអភិវឌ្ឍន៍ (ភាគីធ្វើការងារស្តីពីប្រសិទ្ធភាពជំនួយ) បានត្រូវស្នើសុំអោយបង្កើតក្រុមនេះ ។

**និយមន័យ និងលក្ខខ័ណ្ឌវិនិច្ឆ័យ** : ភាពជាដៃគូរបស់អ្នកផ្តល់ជំនួយ និងប្រទេសដៃគូ ដែលបានរៀបចំធ្វើឡើង ដោយគណៈកម្មការជំនួយអភិវឌ្ឍន៍ (ភាគីធ្វើការងារស្តីពីប្រសិទ្ធភាពជំនួយ)

បានត្រូវស្នើសុំអោយផ្តល់ ការណែនាំអោយបានច្បាស់លាស់ស្តីពីនិយមន័យ ទំហំនៃការអនុវត្តន៍ លក្ខខ័ណ្ឌវិនិច្ឆ័យ និងវិធីសាស្ត្រដើម្បី ធានាថាលទ្ធផលអាចត្រូវបានប្រមូលផ្តុំបូកសរុប តាមពេលវេលាកំណត់ ។

**កំណត់សំគាល់លើសូចនាករទី៩** : អភិក្រមកម្មវិធីបានត្រូវកំណត់ច្បាស់លាស់ក្នុងផ្នែកទី២នៃការអនុវត្តន៍សុខដុមនីយកម្មរបស់អ្នកផ្តល់ជំនួយសំរាប់ប្រសិទ្ធភាពជំនួយ (អង្គការសំរាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ ២០០៥) ក្នុងប្រអប់លេខ៣.១ ដែលមានន័យថាជាមធ្យោបាយចូលរួមក្នុងការអនុវត្តន៍កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដោយផ្អែកលើគោលការណ៍នៃការគាំទ្រសំរាប់កម្មវិធីអភិវឌ្ឍន៍ក្នុងប្រទេសដៃគូ ដូចជា យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ កម្មវិធីតាមវិស័យ កម្មវិធីនានា ឬកម្មវិធីរបស់អង្គការសំខាន់ណាមួយ ។ អភិក្រមតាមកម្មវិធីចែករំលែកនូវលក្ខខ័ណ្ឌដូចតទៅ ÷ (ក)ភាពជាអ្នកដឹកនាំដោយប្រទេសដៃគូ ឬស្ថាប័នដៃគូ (ខ)ក្របខ័ណ្ឌកម្មវិធីនិងថវិកាទូលំទូលាយតែមួយ (គ)ដំណើរការនៃការរៀបចំទំរង់ការសំរាប់សំរបសំរួល និងធ្វើសុខដុមនីយកម្ម នៃនីតិវិធីរបស់អ្នកផ្តល់ជំនួយ សំរាប់ការរៀបចំរបាយការណ៍ថវិកា ការគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្ម (ឃ)កិច្ចប្រឹងប្រែងដើម្បីបង្កើនការប្រើប្រាស់ប្រព័ន្ធរបស់ប្រទេសដៃគូសំរាប់ការរៀបចំកម្មវិធី និងអនុវត្តន៍គំរោងការគ្រប់គ្រងហិរញ្ញវត្ថុ ការត្រួតពិនិត្យនិងវាយតំលៃ ។ សំរាប់គោលដៅនៃសូចនាករទី៩ ការអនុវត្តន៍និងត្រូវវាស់វែងដាច់ដោយឡែក ដោយយោងតាមគំរូបែបបទនៃជំនួយដែលរួមចំណែកទៅក្នុងអភិក្រមតាមកម្មវិធី ។

# ឧបសម្ព័ន្ធ ២
# ប្រទេសនិងស្ថាប័នដែលចូលរួម

## ប្រទេសដែលចូលរួម

Albania
Australia
Austria
Bangladesh
Belgium
Benin
Bolivia
Botswana
Brazil
Burkina Faso
Burundi
Cambodia
Cameroon
Canada
China
Congo D.R.
Czech Republic
Denmark
Dominican Republic
Egypt
Ethiopia
European Commission
Fiji
Finland
France
Gambia
Germany
Ghana
Greece
Guatemala
Guinea
Honduras
Iceland
Indonesia
Ireland
Italy
Jamaica
Japan
Jordan
Kenya
Korea
Kuwait
Kyrgyz Republic
Lao PDR
Luxembourg
Madagascar
Malawi
Malaysia
Mali
Mauritania
Mexico
Mongolia
Morocco
Mozambique
Nepal
Netherlands
New Zealand
Nicaragua
Niger
Norway
Pakistan
Papua New Guinea
Philippines
Poland
Portugal
Romania
Russian Federation
Rwanda
Saudi Arabia
Senegal
Serbia and Montenegro
Slovak Republic
Solomon Islands
South Africa
Spain
Sri Lanka
Sweden
Switzerland
Tajikistan
Tanzania
Thailand
Timor-Leste
Tunisia
Turkey
Uganda
United Kingdom
United States of America
Vanuatu
Vietnam
Yemen
Zambia

## ស្ថាប័នដែលចូលរួម

African Development Bank
Arab Bank for Economic Development in Africa
Asian Development Bank
Commonwealth Secretariat
Consultative Group to Assist the Poorest (CGAP)
Council of Europe Development Bank (CEB)
Economic Commission for Africa (ECA)
Education For All Fast Track Initiative
European Bank for Reconstruction and Development (EBRD)
European Investment Bank (EIB)
Global Fund to Fight Aids, Tuberculosis and Malaria
G24
Inter-American Development Bank
International Fund for Agricultural Development
International Monetary Fund
Millennium Campaign
Islamic Development Bank
Nordic Development Fund
New Partnership for Africa's Development (NEPAD)
Organization for Easter Caribbean States
Organization for Economic Cooperation and Development
Pacific Island Forum Secretariat
OPEC Fund for International Development
World Bank
United Nations Development Group (UNDG)

# អង្គការសង្គមស៊ីវិល

Africa Humanitarian Action
Bill and Melinda Gates Foundation
Comite Catholique contre la Faim et pour le developpement

Commision Economica (Nicaragua)
EURODAD

Japan NGO Center for International Cooperation
Tanzania Social and Economic Trust (TASOET)

AFRODAD
Canadian Council for International Cooperation
Cooperation Internationale pour le Developpement and la Solidarite
ENDA Tier Monde
International Union for Conservation of Nature and Natural Resources (IUCN)
Reality of Aid Network
UK Aid Network